section 2.2.qxp 12/15/2004 1:35 PM Page 1



# ២.២ សិទ្ធិ និងឱកាសចូលរៀន









# ២.២ សិទ្ធិ និងឱកាសចូលរៀន

ផ្នែកនេះនឹងណែនាំអ្នកឲ្យស្គាល់គំនិត គោលនយោបាយ និងបញ្ហាផ្សេងៗដែលទាក់ទងនឹងការអប់រំសំរាប់ទាំងអស់គ្នា–សិទ្ធិមូលដ្ឋានរបស់មនុស្សគ្រប់រូប ។ ជាបឋម យើងនឹងណែនាំអ្នកអំពីទស្សនៈដែលទាក់ទងនឹងសិទ្ធិ និងឱកាសចូលរៀន ឬការទទួលការអប់រំ ។ បន្ទាប់មក យើងលើកសំណួមពររបស់អ្នកក្នុងឋានៈជាអ្នកសារព័ត៌មាន ដែលអាចយកទៅបញ្ចូលក្នុងសេចក្តីរាយការណ៍ព័ត៌មានដែលអ្នកសរសេរអំពីការអប់រំ។

ការអប់រំគឺជាសិទ្ធិមូលដ្ឋានគ្រឹះរបស់ពលរដ្ឋគ្រប់រូប ។ សេចក្តីប្រកាសសកលស្តីពីសិទ្ធិមនុស្ស *(Refer: 2_2_The_Univ_Dec.pdf from CD ROM)* បាននិយាយថា កុមារ យុវវ័យ និងមនុស្ស ពេញវ័យទាំងអស់មានសិទ្ធិទទួលការអប់រំ។ ទោះជាយ៉ាងណាក៏ដោយ ក៏មនុស្សរាប់លាននាក់នៅជុំវិញពិភពលោកមិនដែលមានឱកាសបានចូលរៀនទេ ។ ការបដិសេធន៏សិទ្ធិមិនឲ្យចូលរៀនគឺជាការខាតបង់សក្តានុភាពធនធានមនុស្ស និងរាំងស្ទះដល់ការអភិវឌ្ឍន៏សង្គម សេដ្ឋកិច្ច និងវប្បធ៏ម។ បង្កើតបរិស្ថានអក្ខរកម្មមានតួនាទីសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ទទួលបានសមភាពយេនឌ័រ និង ធានានិរន្តរភាពអភិវឌ្ឍន៏។

**ឯកសារយោង :**

**Region wise educational statistics**—literacy levels in 1970, 2000 (UNESCO statistics) *(Refer: 2_2_regionwise_educational_statistics.pdf from CD ROM)*

**Budget allocations to education by selected countries in 1999**
*(Refer: 2_2_buget allocation to education.pdf from CD ROM)*

បច្ចុប្បន្ននេះ ក្មេង យុវវ័យ និងមនុស្សពេញវ័យមានឱកាសចូលរៀនកាន់តែច្រើន។ បច្ចុប្បន្ននេះមនុស្សចាស់ចំនួន ៣,៣ លាន នាក់ចេះអាន និងចេះសរសេរ — ៣ ដងច្រើនជាងកាលពី ៤០ ឆ្នាំមុន ។ ចំនួនកុមារនៅក្នុងសាលាចេះតែបន្តកើនឡើងជារៀងរាល់ឆ្នាំ ហើយចំនួននេះនឹងចេះតែកើនឡើងបន្តទៀត។

បទពិសោធន៏បង្ហាញថា ឆន្ទៈនយោបាយមោះមុត និងការវិនិយោគលើវិស័យអប់រំដើម្បីធានាផ្តល់សិទ្ធិ និងឱកាសចូលរៀនមានប្រវត្តិយូរលង់ណាស់មកហើយនៅក្នុងការអភិវឌ្ឍន៏សង្គម ។ ប្រទេសជាច្រើនបានរៀបចំច្បាប់ដើម្បីធានាផ្តល់សិទ្ធិ និងបង្កីនវិនិយោគនៅក្នុងវិស័យអប់រំកាន់តែច្រើន។

section 2.2.qxp 12/15/2004 1:35 PM Page 3



# ២.២ សិទ្ធិ និងឱកាសចូលរៀន

## ហិរញ្ញវត្ថុសំរាប់អប់រំ

(Refer: 2_2_Financing_Education.pdf from CD ROM)

តួនាទីរបស់អ្នកសារព័ត៌មាននៅក្នុងការស្វែងយល់ និងដោះស្រាយបញ្ហាអប់រំ និងតាមដានការងាររបស់រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងតាមដានការងាររបស់សង្គមស៊ីវិលមានសារៈសំខាន់ណាស់ ។ ក្នុងនាមជាអ្នកសារព័ត៌មានសរសេរអំពីរឿងរ៉ាវអប់រំ អ្នកត្រូវពិនិត្យមើលច្បាប់នៅក្នុងប្រទេសរបស់អ្នក ហើយវិភាគអំពីការបកស្រាយនៅតាមផ្នែកនីមួយៗនៃច្បាប់ ដោយអ្នកទទួលខុសត្រូវ និងអ្នកអនុវត្តន៍ច្បាប់។

## ករណីសិក្សា

ករណីសិក្សានៃរបាយការណ៍ល្អៗស្តីពីការងាររបស់រដ្ឋាភិបាលក្នុងការជំរុញឲ្យបានសំរេចនូវការអប់រំសំរាប់ទាំងអស់គ្នា ។

ឧទាហរណ៍ទី ១ ប្រទេស **Bangladesh**
ឧទាហរណ៍ទី ២ ប្រទេស **Uganda**
ឧទាហរណ៍ទី ៣ ប្រទេស **Caribbean**

**ឧទាហរណ៍ទី ១ ប្រទេស Bangladesh**
**ដោយ** Tabibul Islam
**សារព័ត៌មាន** Inter Press Service

ថ្ងៃទី ២៥ មេសា (IPS) ប្រាក់ ១៦ ដុល្លា សំរាប់មួយខែ Firoz Kabir និស្សិតសាកលវិទ្យាល័យបានចំណាយពេលវេលាក្នុងពេលសិក្សាមួយចំនួនដើម្បីបង្រៀនក្មេងៗដែលរស់នៅក្នុងតំបន់អនាធិប្បតេយ្យ Jigatola ដែលស្ថិតនៅលាយឡំជាមួយតំបន់លំនៅដ្ឋាននៅក្នុងក្រុងបង់ក្លាដេស ។

ក្រៅពីប្រាក់កាស Kabir មានការពេញចិត្តយ៉ាងខ្លាំងក្នុងការចំណាយពេលវេលាចំនួន ២ ម៉ោងជារៀងរាល់ព្រឹក បង្រៀនក្មេងៗចំនួន ៣០ នាក់នៅសាលាអប់រំក្រៅប្រព័ន្ធ Jigatola ។ ក្មេងៗទាំងនេះរួមមានអ្នកបំរើតាមផ្ទះ អ្នកលក់ដូរតាមផ្លូវ និងទិនិកា (អ្នកធ្វើករយកប្រាក់ប្រចាំថ្ងៃ) ។

សាលានេះស្ថិតនៅក្រោមការចាត់ចែងរបស់អង្គការក្រៅរដ្ឋាភិបាលមួយឈ្មោះ ‘Development For The Poor’ (អង្គការអភិវឌ្ឍន៍ដើម្បីអ្នកក្រ) បង្រៀនចំណេះដឹងមូលដ្ឋានដល់ពួកអ្នកក្រ ។ សិស្សក្រីក្រ ដែលភាគច្រើនជាកុមារី ត្រូវបានគេបែងចែកឲ្យរៀនពីរវេន និងទទួលបានសៀវភៅ និងសំភារៈសិក្សាផ្សេងៗទៀតដោយឥតគិតថ្លៃ ។

section 2.2.qxp 12/15/2004 1:35 PM Page 4



# ២.២ សិទ្ធិ និងឱកាសចូលរៀន

សិស្សភាគច្រើនជាអ្នករកប្រាក់ចំណូលបន្ថែមលើប្រាក់ចំណូលរបស់គ្រួសារដែលរកបានបន្តិចបន្តួច ។ ពួកគេធ្វើជាអ្នកបំរើតាមផ្ទះ អ្នកជួយលក់ដូរតាមហាង អ្នកបំរើតាមសណ្ឋាគារ និងធ្វើជាជាងជួសជុលគ្រឿងម៉ាស៊ីន ។ ក្មេងដែលធ្វើការទាំងអស់នេះគឺជាក្មេងដែលពួកអ្នកជំនាញការហៅថា "ក្មេងដែលគ្មានឬមានឱកាសសិក្សាតិច" នៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់អប់រំសំរាប់ទាំងអស់គ្នា ។

មុនពេលមានសាលាក្រៅប្រព័ន្ធ Jigatola កុមារនៅតំបន់នេះពុំដែលបានចូលរៀនទេ ។ បើតាមប្រសាសន៍របស់លោកគ្រូ Khodeja Akhter ជោគជ័យរបស់គម្រោងអប់រំសំរាប់ទាំងអស់គ្នាអាស្រ័យលើការបង្កលក្ខណៈងាយស្រួលឲ្យពួកក្មេងៗទាំងនេះ "បានរៀនសូត្រផង និងបានរកប្រាក់ចំណូលផង" ។

តាមប្រសាសន៍របស់លោក Kazi Farid Ahmed នាយកអប់រំក្រៅប្រព័ន្ធនៅក្រុងដាកាមានសាលាអប់រំក្រៅប្រព័ន្ធចំនួន ២០២៥ ដែលបង្រៀនចំណេះដឹងមូលដ្ឋានដល់ក្មេងរស់នៅក្នុងតំបន់ក្រីក្រចំនួន ៦០៧៥០ នាក់ ដែលក្នុងនោះ ៥៤ ភាគរយជាក្មេងស្រី ។

ដោយបានទទួលជំនួយពីអង្គការ UNICEF ការគាំទ្រពីរដ្ឋាភិបាលបង់ក្លាដេស និងស៊ុយអែត គម្រោង "អប់រំមូលដ្ឋានសំរាប់កុមារទីក្រុងដែលពិបាកទទួលការអប់រំ [Basic Education for Hard-to-Reach Urban Children (BEHTRUC)] ត្រូវបានបង្កើតឡើងក្នុងគោលបំណងផ្តល់ការអប់រំមូលដ្ឋានក្រៅប្រព័ន្ធដល់កុមារ ៣៥០០០០ នាក់ នៅក្នុងតំបន់ ៦ ចាប់តាំងពីឆ្នាំ ១៩៩៧ ដល់ ឆ្នាំ ២០០២ ។

ក្មេង ១៨០០០០ នាក់នៅក្នុងតំបន់ ៦ (Chittagong, Khulna, Rajshahi, Barisal, Sylhet) របស់ទីក្រុងដាកាបានទទួលការបណ្តុះបណ្តាលការអប់រំមូលដ្ឋានពីគម្រោង BEHTRUC ។ នៅក្នុងរយៈពេល ១៦ ខែបន្ទាប់ទៀត គេសង្ឃឹមថានឹងមានសាលាអប់រំក្រៅប្រព័ន្ធជាច្រើនត្រូវបានបង្កើតឡើងដើម្បីបំរើតម្រូវការរបស់កុមារដែលមានអាយុពី ៨ ទៅ ១៤ ឆ្នាំ ដែលមិនបានចូលរៀន ។ អង្គការក្រៅរដ្ឋាភិបាលចំនួន ១២៥ បានទទួលភារកិច្ចដើម្បីដំណើរការសាលរៀនក្រៅប្រព័ន្ធសំរាប់ជនរស់នៅតំបន់ក្រីក្រដែលជាអ្នករកប្រាក់ចំណូលសំរាប់គ្រួសារ។ ៥៦ ភាគរយនៃជនក្រីក្រទាំងនេះបានទទួលការរៀនសូត្រ។

នៅក្នុងគ្រួសារមួយចំនួន ពលកម្មកុមារអាចរកប្រាក់ចំណូលចំនួន ១ ភាគ ៣ នៃប្រាក់ចំណូលរបស់គ្រួសារទាំងមូល ។ ពួកក្មេងៗទាំងនេះមិនបានរៀនសូត្រ មិនមែនដោយហេតុថា ពួកគេគ្មានពេលនោះទេ នៅកន្លែងខ្លះនៃតំបន់ក្រីក្រនេះគឺគ្មានសាលារសំរាប់ពួកគេតែម្តង។

# ២.២ សិទ្ធិ និងឱកាសចូលរៀន

ការសិក្សារបស់ UNICEF បង្ហាញថា ទោះបីជាមានសាលាក៏ដោយ ក៏ក្មេងៗទាំងនោះមិនអាចចូលរៀនបានដែរ ដោយសារថ្លៃចំណាយលើការសិក្សាច្រើនពេក ។ ដូចនេះ ក្មេងៗទាំងនេះត្រូវបានចាត់ទុកថាជាក្មេងជួបការលំបាកក្នុងការទទួលការអប់រំ។

នៅក្នុងផ្នែកមួយនៃគម្រោងនេះ គ្រូមកពីអង្គការក្រៅរដ្ឋាភិបាលដែលបានចូលរួមក្នុងកម្មវិធីនេះ បានទទួលការបណ្តុះបណ្តាលពិសេសផ្នែកវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល ដែលមានការចូលរួមដោយយកចិត្តទុកដាក់ជាពិសេសលើក្មេងដែលគ្មានឱកាសសិក្សា ។ គ្រូដែលចូលរួមក្នុងគម្រោងតម្រូវឲ្យទៅលេងផ្ទះរបស់សិស្សដើម្បីតាមដានការរីកចំរើនរបស់សិស្ស និងប្រាប់ក្រុមគ្រួសាររបស់សិស្សឲ្យបានដឹងអំពីការរីកចំរើនរបស់កុមារ ។ ដោយបានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ អង្គការស៊ីដា និងភ្នាក់ងារផ្តល់ជំនួយណ័រវេ គម្រោងអប់រំក្រៅប្រព័ន្ធចំនួន ៤ ទៀតដែលមានទឹកប្រាក់សរុបចំនួន ៣០៩ លានដុល្លាកំពុងដំណើរការនៅបង់ក្លាដេស ។

រដ្ឋមន្ត្រីអប់រំ លោក A. Sadique បានប្រាប់សភាបង់ក្លាដេសកាលពីខែមុនថា ជាលទ្ធផលនៃការខិតខំប្រឹងប្រែងរបស់យើង អត្រាអក្ខរកម្មបានកើនឡើងពី ៣៤,៦ នៅឆ្នាំ ១៩៩១ ដល់ ៦០ ភាគរយនៅពេលបច្ចុប្បន្ន ហើយគាត់សង្ឃឹមថានឹងឡើងដល់ ៨០ ភាគរយនៅឆ្នាំ ២០០១ ។

ប៉ុន្តែ ជំនាញការជាច្រើនគិតថា រដ្ឋាភិបាលចាំបាច់ត្រូវបង្កើតគោលនយោបាយដែលមានលក្ខណៈប្រាកដនិយមជាងនេះទៀតដើម្បីដោះស្រាយបញ្ហាក្មេងបោះបង់ការសិក្សា និងក្មេងដែលមិនបានចុះឈ្មោះចូលរៀននៅបឋមសិក្សា ។ ប្រជាជនភាគច្រើននៃប្រជាជនបង់ក្លាដេសចំនួនប្រហែល ១២០ លាននាក់រស់នៅតាមទីប្រជុំជន តាមភូមិ ។

នៅពេលបច្ចុប្បន្ននេះ អត្រានៃការបោះបង់ការសិក្សាមានចំនួន ៣៨ ភាគរយ និងការផ្តល់ការអប់រំដល់ក្មេងដែលបោះបង់ការសិក្សាចំនួន ៥ លាននាក់ និងក្មេងដែលមិនដែលបានចុះឈ្មោះចូលរៀនគឺជាអ្វីដែលរដ្ឋាភិបាលត្រូវប្រឈមមុខដោយចៀសមិនផុត។ បន្ថែមលើនេះទៀត រហូតមកដល់ពេលនេះពុំមានផែនការលំអិតស្តីពីការអប់រំសំរាប់កុមារដែលជាកម្មករ និងមានអាយុពី ៩ ទៅ ១៥ ឆ្នាំទេ ។

Ansar Ali Khan តំណាងអង្គការ UNESCO និងUN នៅបង់ក្លាដេសគាំទ្រការខិតខំប្រឹងប្រែងដើម្បីលុបបំបាត់អនក្ខរភាពឲ្យអស់ពីប្រទេសនៅឆ្នាំ ២០០៦ ។

លោក Khan បន្តទៀតថា "សំរាប់ការងារនេះ រដ្ឋាភិបាលនឹងត្រូវបន្ថែមការវិនិយោគថែមទៀតនៅក្នុងវិស័យអប់រំ និងខិតខំប្រឹងប្រែងបន្ថែមក្នុងការផ្សព្វផ្សាយអំពីការអប់រំឲ្យកាន់តែច្រើន"។

# ២.២ សិទ្ធិ និងឱកាសចូលរៀន

បើតាមរបាយការណ៍របស់អង្គការឃ្លាំមើលការអប់រំ (Education Watch, 1999) នៅពេលបច្ចុប្បន្ន នេះបង់ក្លាដេសចំណាយ ២,៣ ភាគរយនៃផលទុនក្នុងស្រុកសរុបរបស់ខ្លួនលើវិស័យអប់រំ ដែលចំនួនតិចជាងប្រទេសដ៏ទៃទៀតយ៉ាងច្រើន ។

របាយការណ៍បញ្ជាក់ថា ប្រាក់សំរាប់បឋមសិក្សាមានតិចណាស់ ហើយ ៩០ ភាគរយទុកសំរាប់តែប្រាក់ខែគ្រូ បុគ្គលិករដ្ឋបាលប៉ុណ្ណោះ ។

អត្ថបទនេះរក្សាសិទ្ធិគ្រប់យ៉ាង ហើយអាចដកស្រង់បានដោយមានការអនុញ្ញាត និងដាក់ប្រភព Inter Press Service ។

ឧទាហរណ៍ទី ២ : ប្រទេស **Uganda**

**Uganda សំរេចផែនការសកលកម្មអប់រំបឋមសិក្សា**

**ដោយ Dan Elwana**

សារព័ត៌មានអាហ្វ្រិកខាងកើត Kampala, Uganda

ចាប់ផ្តើមកាលពី ៣ ឆ្នាំមុន យុទ្ធសាស្ត្ររបស់ប្រទេស Uganda នៃការអប់រំគ្មានបង់ប្រាក់សំរាប់ទាំងអស់គ្នា — សកលកម្មអប់រំបឋមសិក្សា — កំពុងតែទទួលបានផលល្អប្រសើរ ។ អត្រាចុះឈ្មោះចូលរៀនបានកើនឡើងនៅពេលមានក្មេងកាន់តែច្រើនទៅរៀននៅគ្រប់សាលាទូទាំងប្រទេស។

Vincent Oyat ជាអ្នករកស៊ីដាំ និងនេសាទត្រីនៅតាមដងទន្លេ Lake Kyoga នៅស្រុក Apc មានប្រសាសន៍ថា "ខ្ញុំសប្បាយរីករាយណាស់ ដែលឥឡូវនេះខ្ញុំអាចបញ្ជូនកូនទាំង ៤ នាក់របស់ខ្ញុំឲ្យទៅរៀនបាន ។ ខ្ញុំបង់តែថ្លៃសំលៀកបំពាក់ និងសៀវភៅបន្តិចបន្តួចប៉ុណ្ណោះ ។ នេះគឺជាប្រព័ន្ធអប់រំដែលអាចជួយដល់ប្រជាជននៅក្នុងតំបន់របស់ខ្ញុំ ។ កូនរបស់គាត់បានទៅរៀននៅសាលាក្នុងភូមិមួយដែលមានចំងាយប្រហែល ៣ គីឡូម៉ែត្រពីផ្ទះរបស់គាត់ ។

សកលកម្មបឋមសិក្សាត្រូវបានគេយកមកអនុវត្តនៅ Uganda នៅខែ មករា ឆ្នាំ ១៩៩៧ ជាផ្នែកមួយនៃគោលនយោបាយរដ្ឋាភិបាលដើម្បីផ្តល់ការអប់រំនៅបឋមសិក្សាដោយឥតគិតថ្លៃដល់កូនចំនួន ៤ នាក់ នៅក្នុងគ្រួសារនីមួយៗ រួមបញ្ចូលទាំងក្មេងកំព្រា និងក្មេងពិការ ។ ដោយមានការអនុវត្តគោលនយោបាយសកលកម្មបឋមសិក្សា Uganda សង្ឃឹមថា គោលនយោបាយនេះនឹងមានឥទ្ធិពលធំធេងលើ អនាគតវិស័យអប់រំនៅ Uganda។

section 2.2.qxp 12/15/2004 1:36 PM Page 7



# ២.២ សិទ្ធិ និងឱកាសចូលរៀន

នៅក្នុងការអនុវត្តកម្មវិធីនេះ Uganda បានគិតគូរទុកជាមុនរួចស្រេចនៅបញ្ហាលំបាកផ្នែកហិរញ្ញវត្ថុ និងតម្រូវការក្នុងការផ្តល់ការអប់រំមូលដ្ឋានប្រកបដោយប្រសិទ្ធភាព ។ ការឆ្លើយតបដ៏ច្រើនលើសលុបមកពី ទូទាំងប្រទេស ធ្វើឲ្យរដ្ឋាភិបាលត្រូវប្រឈមមុខនឹងបញ្ហាមួយចំនួន ដូចជាបុគ្គលិក និងសំភារៈសិក្សា ។ តួលេខនៃការចុះឈ្មោះចូលរៀនបានកើតនឡើងពី ២,៥ លាននាក់ នៅឆ្នាំ ១៩៩៧ ទៅ ៦,៥ លាននាក់ នៅបច្ចុប្បន្ន ។

នៅតំបន់ខ្លះនៃទំនាបកណ្តាលប្រទេស Uganda ការចុះឈ្មោះចូលរៀនមានចំនួនច្រើនលើសលុបពេកដែលជាហេតុធ្វើឲ្យសិស្សមួយចំនួនត្រូវរៀនក្រោមដើមឈើ ។ នៅទីប្រជុំជនក្រុងសាលាដែលទទួលជំនួយពីរដ្ឋាភិបាលក៏មានអត្រាចុះឈ្មោះចូលរៀនច្រើនលើសលុបដែរជាហេតុបង្កឲ្យមានបញ្ហាជាច្រើនទាក់ទងនឹងបញ្ហាគុណភាពអប់រំ ដែលលើកឡើងដោយអ្នកនយោបាយប្រឆាំង ។

អ្នកអប់រំ និងអ្នករៀបចំគោលនយោបាយ ជឿជាក់ថា ដោយមានការឆ្លើយតបដ៏ច្រើនលើសលុបបែបនេះ ក្របខ័ណ្ឌមួយត្រូវតែរៀបចំដើម្បីដោះស្រាយបញ្ហាដែលយើងត្រូវប្រឈមមុខ និងការលំបាកទាំងឡាយនៅខាងមុខយើង ។ ផែនការវិនិយោគលើវិស័យអប់រំត្រូវបានបង្កើតឡើងសំរាប់រយៈពេលពីឆ្នាំ ១៩៩៧ ដល់ឆ្នាំ ២០០៣។ ផែនការនេះបានទទួលការយល់ព្រមនៅខែធ្នូ ឆ្នាំ ១៩៩៨។ រដ្ឋាភិបាលបាននិយាយថា ផែនការនេះធ្វើឡើងឈរលើមូលដ្ឋានគោលនយោបាយរបស់រដ្ឋាភិបាលឆ្នាំ ១៩៩២ (Government White Paper) នៅក្នុងរបាយការណ៍ពិនិត្យគោលនយោបាយអប់រំ (Education Policy Review Commission Report) ។

ប្រធានាធិតី Uganda លោក Yoweri Museveni ដែលជាអ្នកគាំទ្រយ៉ាងខ្លាំងលើកម្មវិធីសកលកម្មអប់រំបឋមសិក្សា ដែលគាត់បានប្រើប្រាស់នៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោតនៅអំឡុងឆ្នាំ ១៩៩៦ មានប្រសាសន៍ថា គម្រោងវិនិយោគលើវិស័យអប់រំនឹងជួយយើងឲ្យលុបបំបាត់ភាពក្រីក្រពីព្រោះគម្រោងនេះនឹងផ្តល់ឲ្យយើងនូវក្របខ័ណ្ឌសំរាប់វិនិយោគដើម្បីប្រែក្លាយចក្ខុវិស័យនេះឲ្យទៅជាការពិតតាមរយៈការអប់រំ ។

លទ្ធផលរបស់សកលកម្មអប់រំបឋមសិក្សាគឺមួយផ្នែកបានមកពីការខិតខំប្រឹងប្រែងឥតឈប់ឈរក្នុងចន្ទុះនយោបាយមួយ ដើម្បីអប់រំមាតាបិតា អំពីអត្ថប្រយោជន៏របស់ការអប់រំបឋមសិក្សាដែលមិនបង់ថ្លៃ ។ បេសកជនតាមស្រុក និងមន្ត្រីអប់រំស្រុក គឺជាអ្នកមានតួនាទីក្នុងការអនុវត្តកម្មវិធីនេះ ដោយធានាឲ្យបានជោគជ័យនៅតាមភូមិ ឃុំ។ ថ្នាក់ដឹកនាំមូលដ្ឋានផ្សេងៗទៀតយល់ស្របថាកម្មវិធីនេះត្រូវបានគេតាមដានដោយយកចិត្តទុកដាក់ដើម្បីធានាឲ្យបានផលប្រយោជន៏ពេញលេញសំរាប់ទាំងអស់គ្នា ។

section 2.2.qxp 12/15/2004 1:36 PM Page 8



# ២.២ សិទ្ធិ និងឱកាសចូលរៀន

ពេលនេះ Uganda កំពុងប្រឈមមុខបញ្ហាពយ៉ាង : ឱកាសចូលរៀន សមធម៌ និងប្រសិទ្ធភាព។ គោលដៅគឺថាពង្រីកវិស័យអប់រំដើម្បីឲ្យកុមារកាន់តែច្រើនបានចូលរៀន និងលុបបំបាត់វិសមភាពទាំងឱកាសចូលរៀន និងលទ្ធផលនៃការសិក្សា ដោយយកចិត្តទុកដាក់លើវិសមភាពយេនឌ័រ និងតំបន់ភូមិសាស្ត្រ ។ Uganda ក៏បានពិចារណាពីរឿងពង្រីកការអប់រំនៅមធ្យមសិក្សា និងផ្នែកផ្សេងទៀតផងដែរដើម្បីប្រមូលអ្នកបោះបង់ការសិក្សាឲ្យបានចូលរៀនវិញ ។

ទោះបីជាប្រាក់ឧបត្ថម្ភត្រូវគេផ្ញើរពីរដ្ឋាភិបាលកណ្តាលសំរាប់សកលកម្មបឋមសិក្សាក៏ដោយ គេក៏បានយកចិត្តទុកដាក់ក្នុងការឲ្យមានការចូលរួមពីមាតាបិតាសិស្សដែរ ជាពិសេសក្នុងការសង់សាលា ផលិតឥដ្ឋ និងការផ្តល់ដីសំរាប់សាងសង់សាលា ។ បន្ថែមលើការសាងសង់បន្ទប់រៀន ៥២០០០ និង១២០០០ ដែលបានបញ្ចប់នៅឆ្នាំនេះ Uganda ក៏មានបំណងបោះពុម្ព និងចែកចាយសៀវភៅសិក្សាឲ្យសិស្សម្នាក់មួយក្បាលដែរ ។

ការយកចិត្តទុកដាក់ក៏បានសង្កត់ធ្ងន់លើការបណ្តុះបណ្តាលវិក្រឹត្យការសំរាប់គ្រូដើម្បីឲ្យគ្រូមានសមត្ថភាពផ្តល់ការអប់រំមួយដែលមានគុណភាព។ ចំណែកមធ្យមសិក្សាវិញ រដ្ឋាភិបាលមានគោលបំណងឲ្យមានសាលាមធម្យមសិក្សាមួយនៅគ្រប់ស្រុក ។

បន្ថែមទៅលើការពង្រីកសកលកម្មបឋមសិក្សា និងUganda មានផែនការសាងសង់ មជ្ឈមណ្ឌលពហុបច្ចេកទេសតាមសហគមន៍ចំនួន ៨៥០ ដើម្បីបណ្តុះបណ្តាលជំនាញបច្ចេកទេសមូលដ្ឋានដល់កុមារបោះបង់ការសិក្សា ។ អនុផ្នែកអប់រំ និងវិជ្ជាជីវៈក៏មានបញ្ចូលនៅក្នុងផែនការវិនិយោគវិស័យអប់រំដែរ ។ ទោះបីជាគ្មានចំនួនថវិកាពិតប្រាកដ រដ្ឋាភិបាលនិយាយថា រដ្ឋាភិបាលបានរៀបចំកញ្ចប់ថវិកាមួយចំនួនសំរាប់ជួសជុលមជ្ឈមណ្ឌលពហុបច្ចេកទេសចាស់ៗ និងឧត្តមសិក្សាមួយចំនួនសំរាប់ដំណើរការកម្មវិធី ។ ដើម្បីជាសញ្ញាបង្ហាញថារដ្ឋាភិបាលប្តេជ្ញាចិត្តចំពោះគោលនយោបាយអប់រំសំរាប់ទាំងអស់គ្នា ការចំណាយរបស់រដ្ឋាភិបាលបានកើនឡើងចំនួន ៣០ ភាគរយពីចំនួន USh 44 កោដិ នៅឆ្នាំ ១៩៩៦ ដល់ USh136 កោដិ នៅឆ្នាំ ១៩៩៨ ។ រហូតមកដល់ខែមិនា ឆ្នាំ ១៩៩៩ ប្រាក់ចំនួន USh6.22 កោដិ ត្រូវបានបែងចែកសំរាប់ការសាងសង់សាលាបឋមសិក្សានៅក្នុងស្រុកចំនួន ៨ គឺ Kabarole, Bugiri, Pallisa, Kiboga, Arua, Moyo, Nebbi and Adjumani ។

ប្រាក់ជំនួយសំរាប់សកលកម្មអប់រំបឋមសិក្សានៅ Uganda បានមកពីធនាគារពិភពលោក រដ្ឋាភិបាល ហូឡង់ ដាណឺម៉ាក ចក្រភពអង់គ្លេស និងUSAID ។

# ២.២ សិទ្ធិ និងឱកាសចូលរៀន

**ឧទាហរណ៍ទី ៣ : ប្រទេស Caribbean**

"អប់រំសំរាប់ទាំងអស់គ្នា" គោលដៅនៅឆ្ងាយពីរដ្ឋាភិបាលក្នុងតំបន់ Caribbean
ដោយ By Wesley Gibbings
Inter Press Service

កំពង់ផែអេស្ប៉ាញ ខែមេសា ថ្ងៃទី ១១ — អស់រយៈពេលជិត ១០ ឆ្នាំមកហើយបន្ទាប់ពីពិភពលោកបានកំណត់គោលដៅអប់រំសំរាប់ទាំងអស់គ្នានៅឆ្នាំ ២០០០ ឲ្យទៅអ្នកជំនាញរបស់អង្គការសហប្រជាជាតិ ។ គោលដៅនេះហាក់ដូចជានៅឆ្ងាយសំរាប់ប្រទេសកំពុងអភិវឌ្ឍន៏នានាដែលតែងតែមិនអាចសំរេចគោលដៅបាន ។

ថវិកាសំរាប់អប់រំធ្លាក់ចុះ ហេដ្ឋារចនាសម្ព័ន្ធកំពុងត្រូវការជាបន្ទាន់ ហើយនៅគ្រប់តំបន់ទាំងអស់ទូទាំងអាមេរិកឡាទីន និងការាប៊ីន មានការព្រួយបារម្ភរួមមួយអំពីអនក្ខរកម្មវិជ្ជាជីវៈ និងឥទ្ធិពលនៃភាពគ្មានការងារធ្វើ និងភាពក្រីក្រ ។

មានឧទាហរណ៍ជាច្រើនដែលបង្ហាញថាការសាងសង់សាលាថ្មីជាច្រើន ពុំមានន័យថា ការអប់រំកាន់តែល្អប្រសើរនោះទេ ។ រដ្ឋាភិបាលនៅក្នុងតំបន់កំពុងតែប្រឈមមុខនឹងបញ្ហាដែលទាក់ទងទៅនឹងការងារដែលគេកំពុងតែចំណាយប្រាក់ជាច្រើន ។

ការស្រាវជ្រាវមួយដោយ Oxfam អង្គការក្រៅរដ្ឋាភិបាលរបស់អង់គ្លេស ប៉ាន់ស្មានថា មានកុមារចំនួន ១២៥ លាននាក់នៅក្នុងពិភពលោកមិនបានចូលសាលា និងមានមនុស្សពេញវ័យចំនួន ៨៧២ លាននាក់ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៏ជាអនក្ខរជន ។ ការសិក្សាមួយទៀតដោយធនាគារអន្តរអាមេរិក (Inter-American Development Bank (IDB) បានបង្ហាឲ្យឃើញថានៅអាមេរិកឡាទីន មានតែក្មេង ១ នាក់ ក្នុងចំណោក្មេង ៣ នាក់ បានរៀនដល់មធ្យមសិក្សា ។

នៅតំបន់ផ្សេងទៀតនៃការាប៊ីន ដែលនិយាយភាសាអង់គ្លេសហាក់ដូចជាមានស្ថានភាពល្អប្រសើរជាង ដោយមានកុមារចំនួន ៨៥ ភាគរយនៃប្រទេស Trinidad & Tobago បានរៀនដល់មធ្យមសិក្សា ។ ប៉ុន្តែមានការព្រួយបារម្ភយ៉ាងខ្លាំងពីអក្ខរកម្មវិជ្ជាជីវៈ ឱកាសចូលរៀននៅឧត្តមសិក្សារបស់សិស្សដែលរៀនចប់មធ្យមសិក្សា ។

# ២.២ សិទ្ធិ និងឱកាសចូលរៀន

ការពិនិត្យតាមដានរបស់ប្រទេសនីមួយៗក្នុងការរៀបចំសំរាប់វេទិកាអប់រំពិភពលោក នៅទីក្រុងដាកាប្រទេស Senegal បញ្ជាក់ឲ្យឃើញថា ទោះបីជាមានការរីកចំរើនលើវិស័យអប់រំទូទាំងពិភពលោកនេះការរីកចំរើនផ្នែកគុណភាពមិនមានដំណើរលឿនដូចបរិមាណទេ ។

ការវាយតម្លៃនេះ និងការវាយតម្លៃផ្សេងទៀត និងយុទ្ធវិធីមានប្រសិទ្ធភាព ដែលបានពិភាក្សានៅក្នុង សន្និសីទតំបន់ទាំង ៦ នៅចន្លោះខែធ្នូ ឆ្នាំ ១៩៩៩ និងខែ កុម្ភៈ ឆ្នាំ ២០០០ នឹងត្រូវលើកយកមកបង្ហាញ នៅក្នុងការប្រជុំនៅដាកា ។

Koochiro Matsuura, អគ្គនាយករបស់អង្គការយូណេស្កូបានពន្យល់នៅក្នុងការប្រជុំនៅការ៉ូសំរាប់រដ្ឋអារ៉ាប់ និងអាមេរិកខាងជើង កាលពីខែ មករា ២៤-២៧ ។ "ដំណើរការនៃការវាយតម្លៃការអប់រំសំរាប់ទាំងអស់គ្នាគឺនិយាយអំពីការរៀនសូត្រពីគ្នាទៅវិញទៅមកពីបទពិសោធន៍មួយទសវត្សរ៍កន្លងមកដើម្បីសំរេចជោគជ័យកាន់តែច្រើននៅទសវត្សរ៍ក្រោយទៀត" ។

គាត់បន្តទៀតថា "យើងត្រូវតែប្រាកដនិយមនៅក្នុងគោលដៅរបស់យើង ការវាស់ និងតាមដានការរីកចំរើន និងជាពិសេសទៅទៀតគឺយើងត្រូវមានមហិច្ឆិតាសំរាប់ថ្ងៃអនាគត ។ ការដែលគេមិនអាចសំរេចគោលដៅអប់រំសំរាប់ទាំងអស់គ្នាពុំមែនជាអ្វីដែលថ្មីនោះទេ ។

នៅក្នុងការប្រជុំកន្លងទៅរបស់អាមេរិកនៅប្រទេសឈីលីនៅឆ្នាំ ១៩៩៨ នាយករដ្ឋមន្ត្រីរបស់ប្រទេស Jamaica លោក Percival Patterson បានព្រមានថា បើគេមិនបានធ្វើអ្វីមួយសំរាប់ការអប់រំនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ទេនោះ "គម្លាតដែលមានស្រាប់រវាងប្រទេសអភិវឌ្ឍន៏ និងប្រទេសកំពុងអភិវឌ្ឍន៏នឹងកាន់តែធំនៅក្នុងរបបពាណិជ្ជកម្មថ្មីនេះ ។

គាត់បានមានប្រសាសន៏ថាការអប់រំមិនមែនគ្រាន់តែប្រាក់នោះទេ ធនាគារអភិវឌ្ឍអន្តរជាតិ និងធនាគារពិភពលោកបានឲ្យប្រាក់កំចីចំនួន ៨,៣ លានដុល្លាសំរាប់ការអប់រំនៅអាមេរិកប៉ុន្តែនេះគឺជាការផ្តួចផ្តើមគំនិតថ្មី ។

គេគួរយកចិត្តទុកដាក់លើការអភិវឌ្ឍន៏យុទ្ធសាស្ត្រថ្មីៗសំរាប់ការអប់រំកុមារតូច ការវាយតម្លៃ និងអាំងឌីកាទ័រ និងការបង្កើតសៀវភៅមេរៀន និងសំភារៈសិក្សាផ្សេងៗទៀតដែលរួមបញ្ចូលគម្រោងបច្ចេកវិទ្យា និងកម្មវិធីសិក្សាផងដែរ ។

# ២.២ សិទ្ធិ និងឱកាសចូលរៀន

តើប្រទេសនៅអាមេរិក និងការាប៊ីនចំណាយប៉ុន្មានលើវិស័យអប់រំ ? Brazil, Costa Rica and Cuba ចំណាយប្រហែល ៦ ភាគរយប្រចាំឆ្នាំ នៅពេលប្រទេសមួយចំនួនដូចជា El Salvador, Guatemala និងPeru ចំណាយតិចជាង ២,៥ ភាគរយ ។

ចំនួននេះខុសគ្នាយ៉ាងខ្លាំងពីសហរដ្ឋអាមេរិកដែលគេចំណាយចំនួន ៩,៨ នៃការចំណាយសាធារណៈលើវិស័យអប់រំ និង១៦,៧ ភាគរយនៅម៉ិកស៊ិចកូ និង១៤,២ ភាគរយនៅ កូរេខាងត្បូង ។

ឥឡូវនេះប្រទេសនៅអាមេរិកបានសន្យាថានឹងបង្កើនប្រាក់ចំណាយកាន់តែច្រើនសំរាប់វិស័យអប់រំ ដើម្បីធានាសំរេចនូវការចុះឈ្មោះចូលរៀននៅបឋមសិក្សាឲ្យបាន ១០០ ភាគរយ នៅឆ្នាំ ២០១០ និងបាន ៧៥ ភាគរយនៅមធ្យមសិក្សានៅឆ្នាំដូចគ្នា ។

ការបែងចែកប្រាក់នៅពេលនេះសំរាប់វិស័យសង្គមកិច្ច រួមបញ្ចូលទាំងអប់រំ មិនបានជិតដល់ការផ្តួចផ្តើមគំនិង"២០/២០ ដូចបានសំរេចនៅក្នុងកិច្ចប្រជុំកាលពីឆ្នាំ១៩៩៥ នៅ Copenhagen ទេ។ ស្ថិតនៅក្នុងគំនិតច្នៃប្រឌិតនេះ ប្រទេសឧស្សាហកម្ម យ៉ាងហោចណាស់ ត្រូវផ្តល់ចំនួន ២០ ភាគរយនៃថវិកាជំនួយដល់សេវាសង្គមកិច្ច នៅពេលដែលប្រទេសកំពុងអភិវឌ្ឍត្រូវបំរុង ២០ ភាគរយនៃថវិកាជាតិសំរាប់ផ្នែកនេះ ។

កាលពី ២ ឆ្នាំកន្លងទៅនេះ ប្រធានស្តីទីរបស់ធនាគារពិភពលោកគឺលោក Sven Sandstrom ដែលមានប្រសាសន៏នៅប្រទេស Chile បាននិយាថា ប្រទេសអាមេរិក និងការាប៊ីនមានការរីកចំរើនផ្នែកអប់រំ ប៉ុន្តែបញ្ហាដែលត្រូវប្រឈមមុខនៅមានជាច្រើនទៀត ។

គាត់បានរៀបរាប់ថាបញ្ហាប្រឈមមុខទាំងនេះរួមមាន គុណភាពសិក្សានៅទាប អត្រាត្រួតថ្នាក់ខ្ពស់ និងការមិនបានចូលរៀនរបស់អ្នកក្រីក្រនៅក្នុងសាលាល្អ។ ឱកាសវិសមភាពនៅក្នុងវិស័យអប់រំកាន់តែច្រើនឡើងនៅគ្រប់វណ្ណៈនៅក្នុងសង្គម ។

នាយករដ្ឋមន្ត្រីរបស់ប្រទេស Barbados ឈ្មោះ Owen Arthur ដែលបានចាត់ទុការអប់រំថាជា "សំភារៈមូលដ្ឋានគ្រឹះ" មានប្រសាសន៏ថាមិនត្រឹមតែជួយយើងក្នុងការពង្រីងវិស័យផ្សេងៗរបស់សង្គមទេ ប៉ុន្តែថែមទាំងជួយជំរុញឲ្យមានការរីកចំរើនខាងសេដ្ឋកិច្ចផងដែរ ។

គាត់បន្ថែមថា នេះគឺជាអ្វីដែលមានសារៈសំខាន់បំផុតដល់ការរីកចំរើន និងការអភិវឌ្ឍន៏ដែលមាននិរន្តរភាពសំរាប់ជាតិយើង ។

section 2.2.qxp 12/15/2004 1:36 PM Page 12



# ២.២ សិទ្ធិ និងឱកាសចូលរៀន

បើតាមព័ត៌មានដែលចេញផ្សាយពីលេខាធិការដ្ឋានរបស់វេទិកាអប់រំពិភពលោកនៅក្រុងដាកា ការវាយតម្លៃតាមប្រទេសនីមួយៗ ដែលបានធ្វើកន្លងមកបង្ហាញឲ្យឃើញថា ការខិតខំប្រឹងប្រែង ដើម្បីសំរេចឲ្យបានការអប់រំសំរាប់ទាំងអស់គ្នាគឺជាការចាំបាច់ ។

របាយការណ៍បានបន្តទៀតថា ”បើការប្តេជ្ញាចិត្តជាថ្មីរបស់អ្នកនយោបាយក្នុងការធ្វើសកលកម្ម អប់រំបឋមសិក្សាទេនោះ គោលដៅដែលបានកំណត់នៅឆ្នាំ ១៩៩០ ដោយឲ្យកុមារទាំងអស់បាន ចូលរៀននឹងពិបាកសំរេចបានណាស់ ។

រដ្ឋាភិបាលតាមតំបន់នីមួយៗសង្ឃឹមថាវេទិកា Senegal នឹងបន្ថែមខ្លឹមសារសំខាន់ទៀតនៅក្នុង ដំណើរការនេះ ។





# ២.២ សិទ្ធិ និងឱកាសចូលរៀន

## ២.២.១ យេនឌ័រ

នៅតាមតំបន់ជាច្រើនលើពិភពលោក ប្រជាជនភាគច្រើន ជាពិសេសកុមារី និងស្ត្រីនៅតែជាអនក្ខរជន និងមិនបានសិក្សាវែងឆ្ងាយ ។ នៅមជ្ឈឹមបូពាណ៍ អាស៊ីខាងត្បូង និងអនុតំបន់អាហ្វ្រិកសាហារា ស្ថានភាពអប់រំកាន់តែយ៉ាប់យឺនទៅៗ ។ ដោយពុំបានទទួលការអប់រំឲ្យបានត្រឹមត្រូវ កុមារី និងស្ត្រីត្រូវបាន បដិសេធន៏មិនឲ្យរៀនសូត្រ គ្មានចំណេះដឹង និងជំនាញដែលចាំបាច់សំរាប់ការរស់នៅក្នុងសង្គម។



# ២.២ សិទ្ធិ និងឱកាសចូលរៀន

## ២.២.២ សិទ្ធិកុមារ

ការរៀនសូត្រចាប់ផ្តើតាំងពីកើតមកម្ល៉េះ ។ ទោះជាយ៉ាងនេះក្តី កុមាររាប់លាននាក់មិនបានចូលរៀនទេ។ ជាប់ក្នុងអន្ទាក់ក្រីក្រ និងភាពមិនចេះអក្សរ កុមារត្រូវបង្ខំចិត្តធ្វើជាអ្នកសុំទាន អ្នករើសអេតចាយ ជួយធ្វើការឪពុកម្តាយ អាចជាការងារផ្ទះ ឬការងារស្រែចំការ ជាកម្មករក្នុងការដ្ឋានសំណង់ ឬ រោងចក្រ ។ ពួកគេបានកំរៃយ៉ាងតិចបំផុត តែធ្វើការធ្ងន់ហួសកំលាំង ទទួលការបង្ខិតបង្ខំ និងបាត់បង់សិទ្ធិជាកុមារភាពរបស់ខ្លួន ។ ក្នុងចំណោមកុមារទាំងនេះ ក្មេងស្រីជាអ្នកទទួលរងផលប៉ះពាល់ខ្លាំងជាងគេ ដោយសារ រនាំងវប្បធម៌ និងប្រពៃណី ។

បញ្ហានេះត្រូវធ្លាក់ក្នុងបន្ទុក និងការទទួលខុសត្រូវរបស់អ្នកសាព័ត៌មានដែលជាអ្នកឃ្លាំមើលសង្គមដើម្បីឆ្លុះបញ្ចាំង និងតំរែតំរង់រដ្ឋាភិបាលឲ្យយកចិត្តទុកដាក់លើបញ្ហាទាក់ទងនឹងការមិនទទួលស្គាល់សិទ្ធិរបស់កុមារ ។ ទន្ទឹមគ្នានេះដែរ វាមានសារៈសំខាន់ណាស់ដែលអ្នកសារព័ត៌មានពិនិត្យមើល និងវាយតម្លៃការខិតខំប្រឹងប្រែងរបស់សង្គមដើម្បីផ្តល់សិទ្ធិ និងអំណាចដល់កុមារតាមរយៈការអប់រំ ។



section 2.2.qxp 12/15/2004 1:36 PM Page 15



# ២.២ សិទ្ធិ និងឱកាសចូលរៀន

## ២.២.៣ អក្ខរកម្ម

អក្ខរកម្មគឺជាអ្វី? អក្ខរកម្មមានន័យលើសពីសមត្ថភាពក្នុងការអាន សរសេរ និងគិតលេខ ។ អក្ខរកម្មរួមមានជំនាញផ្សេងៗ ដែលចាំបាច់សំរាប់ឲ្យមនុស្សម្នាក់ៗមានភាពម្ចាស់ការ និងសមត្ថភាពដើម្បីបំពេញតួនាទីប្រកបដោយប្រសិទ្ធភាព ។ អក្ខរកម្មអាចរាប់បញ្ចូលទាំងការអានការណែនាំនានាសំរាប់ប្រើប្រាស់ជីគីមី ឬវេជ្ជបញ្ជា ដឹងថាតើត្រូវឡើងជិះរថយន្តក្រុងមួយណា រក្សាបញ្ជីចំណូលចំណាយសំរាប់ការរកស៊ីតូចតាច ឬប្រើប្រាស់កុំព្យូទ័រជាដើម ។ អក្ខរកម្មអាចជួយយើងឲ្យចេះម្ចាស់ការលើខ្លួនឯង និងទទួលខុសត្រូវចំពោះជីវភាព និងការរស់នៅសមរម្យ ។

ក្នុងនាមជាអ្នកសារព័ត៌មានធ្វើរបាយការណ៍ពីបញ្ហាអក្ខរកម្មមានសារៈសំខាន់ណាស់ដែលអ្នកត្រូវញែកឲ្យដាច់ពីគ្នារវាងអក្ខរកម្មមូលដ្ឋាន ដែលនិយាយអំពីអំណាន សរសេរ និងគិតលេខ និងអក្ខរកម្មវិជ្ជាជីវៈសំរាប់បំពេញតួនាទីប្រចាំជីវិត ។

អ្នកសារព័ត៌មានត្រូវពិនិត្យមើលបញ្ហានៅក្នុងសាច់រឿងដែលបង្ហាញពីរបៀបដែលមនុស្សម្នាក់ៗបានប្រើប្រាស់នូវអ្វីដែលគេបានរៀនពីថ្នាក់អក្ខរកម្ម និងគម្រោងនានា និងពីរបៀបដែលចំណេះដឹងទាំងនេះធ្វើឲ្យជីវិតរបស់ពួកគេមានការប្រែប្រួល ។

អ្នកសារព័ត៌មានត្រូវសិក្សាពីបរិការ និងទំនាក់ទំនងរវាងស្ថិតិអប់រំ និងសាច់រឿងនៃការតស៊ូរបស់មនុស្ស និងការរីកចំរើនរបស់គេ ដែលបានមកពីការខិតខំរបស់មនុស្សម្នាក់ៗរហូតដល់ក្លាយជាអ្នកចេះដឹងដូចគេដូចឯង ។



# ២.២ សិទ្ធិ និងឱកាសចូលរៀន

## ២.២.៤ សហគមន៍ដាច់ស្រយាល និងជួបការលំបាក

ស្ថានភាពកាន់តែយ៉ាប់យ៉ឺននៅក្នុងប្រទេសដែលខ្វះចខ្វាំដោយសារសង្គ្រាម និងការបះបោរស៊ីវិល ការឆ្លងរាលដាលមេរោគ/ជំងឺអេដស៍ ឬនៅក្នុងប្រទេសដែលមានបែងចែកវណ្ណៈខ្លាំង ។ សំរាប់ជនរងគ្រោះដោយសារសង្គ្រាម និងវិសមភាពសង្គម ស្ត្រី និងកុមារច្រើនជាជនរងគ្រោះត្រូវចាកចោលលំនៅដ្ឋាន និងក្លាយជាក្មេងកំព្រា បាត់បង់សិទ្ធិទទួលការអប់រំ សិទ្ធិទទួលការថែទាំសុខភាព និងសិទ្ធិក្នុងការរស់នៅ ។ នេះគឺជាសហគមន៏ដែលមានការអន់ថយ ។

អ្នកសារព័ត៌មានដែលធ្វើរបាយការណ៍ពីបញ្ហាអប់រំត្រូវតែយល់ និងធ្វើរបាយការណ៍អំពីផលលំបាកដែលបណ្តាលមកពីការបាត់បង់ឱកាសសិក្សារបស់ប្រជាជនរស់នៅក្នុងសហគមន៏អន់ថយ និងជួបការលំបាក។ ការបង្កអំពើហិង្សា ភាពមិនចេះអត់ឱន និងអាកប្បកិរិយាផ្តាំផ្គងអាចនឹងត្រូវបានគេឃើញកើតមានញឹកញាប់នៅក្នុងកន្លែងដែលប្រជាជនបាត់បង់សិទ្ធិ ។

ចូរពិនិត្យមើលនៅក្នុងប្រទេស និងវប្បធម៌របស់អ្នកនូវជំលោះណាមួយ ពិនិត្យមើលថាតើជំលោះធ្វើឲ្យប៉ះពាល់ដល់អ្នកក្រ ជនអន្តោប្រវេសន៏ និងអ្នកគ្មានទីលំនៅដោយរបៀបណា ។ ធ្វើរបាយការណ៍ពីរបៀបដែលរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល អាចផ្តល់ការអប់រំសំរាប់ទាំងអស់គ្នា ។

